សួស្តីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

HAPPY KHMER NEW YEAR

ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ
ព្រមទាំងក្រុមគ្រួសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ

សូមគោរពជូន

ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ
ប្រធានក្រុមប្រឹក្សាខេត្តកោះកុង
ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

ឯកឧត្តម ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

ក្នុងឱកាសដ៏មហាទក្ខិណាបូជា ប្រកបដោយសេចក្ដីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខាងមុខនេះ: តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសទ្ធាសាធុការពរដ៏ល្អ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ: **ឯកឧត្តមសន្តិបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរ: កម្លាំងកាយមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយឺនឃ្យះ ដើម្បីមានចំណែកជាមួយការជរដ្ឋាភិបាលក្នុងការដឹកនាំប្រទេសជាតិឱ្យកាន់តែរីកចំរើន ឆ្ពោះទៅកាអភិវឌ្ឍ ប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយរុងរឿង។

ឡៃកក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ: យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្ដីគោរពដ៏ស្មោះស្ម័គ្រចំពោះ: **ឯកឧត្តមសន្តិបណ្ឌិត** ដែលជានិច្ចកាលតែងតែបានខិតខំបំពេញបេសកកម្មជាតិដ៏ថ្លៃថ្នូ ប្រកបដោយភាពស្មោះត្រង់ និងការទទួលខុសត្រូវខ្ពស់ក្នុងការជំរុញ ការអនុវត្តវិធានការយុទ្ធសាស្ត្របញ្ចកោណ ជំណាក់កាលទី១ ដើម្បីបន្តលើកកម្ពស់ប្រសិទ្ធភាពលើយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន សំដៅលើកកម្ពស់ជីវសុខុមាលភាពប្រជាពលរដ្ឋ ដែលជាកត្តារួមចំណែកដ៏មានសារៈសំខាន់ សំដៅជានាវ៉ាយក្សស្ថិរភាពសង្គម សណ្ដាប់ធ្នាប់សាធារណៈ និងភាពសុខដុមរមនាក្នុងសង្គមជាតិកម្ពុជា។

ជាចុងក្រោយទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងសំណូមពរដល់ព្រះរតនត្រ័យ និងវត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះព្រំនូវសទ្ធាសាធុការពរដ៏ល្អ ជូន **ឯកឧត្តមសន្តិបណ្ឌិត** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ: សុខ: ពលៈ: កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ ប្រធានក្រុមប្រឹក្សាខេត្តកោះកុង** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ១២ ឆ្នាំ២០២៦

ឧបនាយករដ្ឋមន្ត្រី ជ្រើមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ម៉ៀ សីហា

ទីស្នាក់ការ៖ សង្កាត់ទន្លេបាសាក ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ៨៨៣ ២១៨ email: generalsec@mod.gov.kh